**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ........................ .រ.ស.

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ :** សំណើសុំធ្វើវិសោធនកម្មលើជំពូកទី៣ ត្រង់មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

**យោង :** ប្រការ ២៦ និងប្រការ ២៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមធ្វើវិសោធនកម្មលើមាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដូចខាងក្រោមៈ

*__*មាត្រា ១៦ :*__ ថវិកា និងធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

វាក្យខណ្ឌទី១ សុំកែមកជា ***ស្ថាប័នប្រឆាំងអំពើពុករលួយមានថវិកាស្វយ័តគ្រប់គ្រាន់ និងទទួលបានដោយទៀតទាត់ ទៅតាមច្បាប់ដែលរដ្ឋសភាបានអនុម័ត ដើម្បីបំពេញតួនាទីភារកិច្ចរបស់ខ្លួន អោយមានប្រសិទ្ធភាព*** ។

វាក្យខណ្ឌទី៣ សុំកែមកជា ***ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ជាអាណាប័កដើមខ្សែ ចំណែកអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ជាអាណាប័កផ្ទេរសិទ្ធិ*** ។

វាក្យខណ្ឌទី៤ សុំកែមកជា ***ការគ្រប់គ្រង និងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវកំណត់ដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ*** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចប្រធានរដ្ឋសភា មេត្តាពិនិត្យដាក់សំណើសុំធ្វើវិសោធនកម្មនេះ ទៅក្នុងសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ ។

សូមសម្តេចប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

**ហត្ថលេខា**

Yim Sovann

Sonchhay

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៩៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ........................ .រ.ស.

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំធ្វើវិសោធនកម្មលើជំពូកទី១ ត្រង់មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

**យោង:** ប្រការ ២៦ និងប្រការ ២៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយស សូមជម្រាបជូនសម្តេចប្រធានបានជ្រាបថា មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយខាងលើនេះ មិនបានចែងឱ្យបានច្បាស់លាស់ពីនិយមន័យនៃពាក្យ "អំពើពុករលួយ" ។ ហេតុដូចនេះ យើងខ្ញុំសូមស្នើធ្វើវិសោធនកម្ម ដោយបន្ថែមនូវខ្លឹមសារទៅក្នុងមាត្រា ៤ ដូចខាងក្រោម:

***-មាត្រា ៤ : និយមន័យអំពើពុករលួយ ត្រូវបានកំណត់អត្ថន័យណាមួយ នៃឃ្លាខាងក្រោមនេះ :***

***ក-គឺជាទង្វើអ្វីមួយរបស់មន្ត្រីនៅគ្រប់លំដាប់ថ្នាក់ នៃស្ថាប័នគ្រប់គ្រងជាតិទាំងអស់ប្រើប្រាស់មុខតំណែងរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍អ្វីមួយសម្រាប់ខ្លួនឯង សំរាប់អ្នកដទៃ ឬសម្រាប់អង្គភាពស្របច្បាប់ណាមួយ តាមរយ: :***

***១-យកទ្រព្យសម្បត្តិរដ្ឋ***

***២-យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬ***

***៣-ទទួលយកសំណូក ទទួលយករង្វាន់ទឹកចិត្ត ឬទទួលយកប្រភេទអំណោយបែបណាមួយក្នុងពេលណាក៏ដោយ ទោះជាមុន ឬក្រោយពេលប្រព្រឹត្តក្តី ឬក្នុងពេលប្រព្រឹត្តក្តី ដើម្បីជាថ្នូរក្នុងការផ្តល់ជាផលប្រយោជន៍អោយមនុស្សម្នាក់ទៀត ។***

***ខ-ជាអំពើណាមួយប្រព្រឹត្តឡើងដោយជនណាម្នាក់ ដែលផ្តល់ជាសំណូកសូកប៉ាន់ ផ្តល់ជារង្វាន់ទឹកចិត្ត ឬប្រគល់ជាអំណោយប្រភេទអ្វីមួយ ក្នុងពេលណាក៏ដោយ ដល់មន្ត្រី ឬនិយោជិកនៅគ្រប់លំដាប់ថ្នាក់នៃស្ថាប័នគ្រប់គ្រងជាតិ ដើម្បីជាថ្នូរសម្រាប់ទាញយកផលប្រយោជន៍ សម្រាប់ខ្លួនឯង សម្រាប់អ្នកដទៃ ឬសម្រាប់អង្គភាពស្របច្បាប់ណាមួយ ។***

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចប្រធានរដ្ឋសភា មេត្តាពិនិត្យដាក់សំណើសុំធ្វើវិសោធនកម្មនេះ ទៅក្នុងសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ ។

សូមសម្តេចប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

**ហត្ថលេខា**

Yim Sovann

យឹម សុវណ្ណ

គួយ ប៊ុនរឿន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ...................... .រ.ស.

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំធ្វើវិសោធនកម្មលើជំពូកទី៤ ត្រង់មាត្រា ២០ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

**យោង:** ប្រការ ២៦ និងប្រការ ២៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមធ្វើវិសោធនកម្មលើមាត្រា ២០ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដូចខាងក្រោម:

* ***មាត្រា ២០ :*** សុំកែមកជា ***ការប្រកាសទ្រព្យសម្បត្តិ និងបំណុល***

***សំណុំឯកសារផ្ទាល់ខ្លួនម្នាក់ៗនៃអ្នកប្រកាសទ្រព្យសម្បត្តិ និងបំណុល ជាឯកសារសាធារណៈ ធ្វើឡើងតាមគំរូដែលកំណត់ដោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ។***

***ព័ត៌មាននៃការប្រកាសទ្រព្យសម្បត្តិ និងបំណុលរបស់មន្ត្រីទាំងនោះ ត្រូវរក្សាទុកនៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអាចត្រូវផ្សព្វផ្សាយជូនដល់សាធារណជន តាមប្រព័ន្ធអេឡិចត្រូនិច ដែលបង្កលក្ខណៈងាយស្រួលដល់អ្នកដែលចង់បានព័ត៌មានទាំងនោះ ។***

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចប្រធានរដ្ឋសភា មេត្តាពិនិត្យដាក់សំណើសុំធ្វើវិសោធនកម្មនេះ ទៅក្នុងសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ ។

សូមសម្តេចប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

**ហត្ថលេខា**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥. ២២០ ៦២៨. ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

លេខ ...................... .រ.ស.

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** សំណើសុំធ្វើវិសោធនកម្មលើ មាត្រា ៥ មាត្រា ៦ មាត្រា ១០ មាត្រា ១១ មាត្រា ១៣ មាត្រា១៤ និងមាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

**យោង:** ប្រការ ២៦ និងប្រការ ២៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមធ្វើវិសោធនកម្មលើមាត្រា ៥ មាត្រា ៦ មាត្រា ១០ មាត្រា ១១ មាត្រា ១៣ មាត្រា ១៤ និងមាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដូចខាងក្រោមៈ

***មាត្រា ៥ :** ស្ថាប័នប្រឆាំងអំពើពុករលួយ

វាក្យខណ្ឌទី១ សុំកែប្រែទៅជា "***ស្ថាប័នប្រឆាំងអំពើពុករលួយរួមមាន ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអគ្គលេខាធិការដ្ឋានប្រឆាំងអំពើពុករលួយ ជាសេនាធិការ***" ។

***មាត្រា ៦ :** ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

វាក្យខណ្ឌទី១ សុំកែប្រែទៅជា "***ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមួយ ដែលជាស្ថាប័នឯករាជ្យ ក្នុងកិច្ចប្រតិបត្តិការងារ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ មានសមាជិក ៥ (ប្រាំ) រូប ដែលមានសមាសភាពដូចខាងក្រោម :***

***-តំណាងជន ២ (ពីរ) រូប តែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់អង្គការសង្គមស៊ីវិល***

***-តំណាងជន៣ (បី) រូបផ្សេងទៀត ជ្រើសតាំងដោយរដ្ឋសភា តាមសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។***

***សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចាំបាច់បំពេញអោយបាននូវលក្ខណៈសម្បត្តិទាំងឡាយ ដូចខាងក្រោម :***

***១-ត្រូវគ្មានជាប់ពាក់ព័ន្ធនឹងសមាជិកភាពគណបក្សនយោបាយណាមួយឡើយ***

***២-ត្រូវមានវិសមតិភាពនឹងមុខងារ ឬមុខតំណែង :***

***-អ្នកតំណាងរាស្ត្រ***

***-សមាជិកព្រឹទ្ធសភា***

***-សមាជិកនៃគណៈរដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាល***

***-មន្ត្រីក្នុងតំណែង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ***

-ព្រះរាជអាជ្ញា ឬចៅក្រម

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

-សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-មន្ត្រីនៃអង្គការរដ្ឋ ឬស្ថាប័នសាធារណៈផ្សេងៗទៀតរបស់រដ្ឋ

៣-ត្រូវគ្មានជាប់ពាក់ព័ន្ធនឹងមុខរបរពាណិជ្ជកម្ម ឬជានិយោជកនៃក្រុមហ៊ុនរដ្ឋចំរុះឯកជន ឬក្រុមហ៊ុនឯកជន ឬអង្គការក្រៅរដ្ឋាភិបាល

៤-ត្រូវមានសីលធម៌ខ្ពស់ និងកេរ្តិ៍ឈ្មោះជាអ្នកស្អាតស្អំ មិនដែលមានទោសព្រហ្មទណ្ឌ

៥-ត្រូវមានកំរិតវប្បធម៌ និងមានសញ្ញាបត្រពិតប្រាកដចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ

៦-ត្រូវមានសញ្ជាតិជាខ្មែរពីកំណើត មានអាយុយ៉ាងតិច ៣៥ឆ្នាំ យ៉ាងច្រើន ៦០ឆ្នាំ និងមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ៧ឆ្នាំ ។

***មាត្រា ១០ :** ភារកិច្ចរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

សុំកែប្រែទៅជា "ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បំពេញភារកិច្ចរបស់ខ្លួនតែក្នុងក្របខ័ណ្ឌជុំវិញរឿងអាស្រូវទាក់ទិននឹងអំពើពុករលួយស៊ីសំណូកសូកប៉ាន់ ការប្រើអំណាចរំលោភ អំពើគេចពន្ធ ជំនួញដូរខុសច្បាប់ និងរឿងអាស្រូវផ្សេងៗទៀត ដែលប៉ះពាល់ដល់កិត្យានុភាពនៃអំណាចសាធារណៈ ។

ក្នុងក្របខ័ណ្ឌខាងលើ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ មានភារកិច្ចដូចតទៅ :

១-ត្រួតពិនិត្យ និងស៊ើបអង្កេតរឿងអាស្រូវនីមួយៗ ដូចមានចែងក្នុងវាក្យខ័ណ្ឌទី១ខាងលើ

២-រៀបចំសំណុំឯកសារ និងភស្តុតាងនៃរឿងអាស្រូវ

៣-កំណត់បង្ហាញ និងលាតត្រដាងនូវរាល់ទង្វើដែលទាក់ទិននឹងក្របខ័ណ្ឌរបស់ខ្លួន និងបុគ្គលដែលពាក់ព័ន្ធនឹងរឿងអាស្រូវ

៤-ចាត់វិធានការសមស្រប និងម៉ឺងម៉ាត់ សំដៅអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធិភាព

៥-កោះអញ្ជើញសាមីជន ពាក់ព័ន្ធនឹងរឿងអាស្រូវ ឱ្យមកស្រាយបំភ្លឺអំពីអង្គហេតុដែលទាក់ទិននឹងបញ្ហាជាប់អង្កេតនានា

៦-មានសិទ្ធិពេញលេញក្នុងការទាមទារយករាល់ឯកសារទាក់ទិននឹងរឿងអង្កេតពីបុគ្គល និងពីស្ថាប័នពាក់ព័ន្ធ

៧-ចេញសេចក្តីសំរេចអំពីលទ្ធផលនៃកិច្ចអង្កេតចំពោះរឿងនីមួយៗ ហើយធ្វើថ្វាយព្រះមហាក្សត្រ និងជូនរដ្ឋសភា ហើយប្រសិនបើក្រុមប្រឹក្សាជាតិប្រឆាំងអំពើរពុករលួយសន្និដ្ឋានថា អាចមានបទល្មើសព្រហ្មទណ្ឌកើតឡើង ក្នុងករណីដោយឡែកណាមួយនោះ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយត្រូវផ្តល់លិខិតចំលង នៃសេចក្តីសំរេចរបស់ខ្លួនមួយ និងភស្តុតាងទាក់ទិននានា ទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាផ្តួចផ្តើមធ្វើការអង្កេតលើបទល្មើសព្រហ្មទណ្ឌណាមួយនោះ ។ ក្នុងរយៈពេល៣០ថ្ងៃ នៃការទទួលសេចក្តីសំរេចពីក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ព្រះរាជអាជ្ញាធ្វើពាក្យបណ្តឹងព្រហ្មទណ្ឌទៅតុលាការ

*ឬពីនោះទេ ត្រូវធ្វើលិខិតពន្យល់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយវិញ ពីមូលហេតុដែលពុំព្រមធ្វើបណ្តឹង ។*

*៨-មានកាតព្វកិច្ច មកស្រោយបំភ្លឺថ្វាយព្រះមហាក្សត្រ តាមការកោះអញ្ជើញរបស់ព្រះមហាក្សត្រ និងជូនប្រជុំពេញអង្គរបស់រដ្ឋសភា តាមការស្នើសុំពីប្រធានរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអ្នកតំណាងរាស្ត្រយ៉ាងតិចមួយភាគដប់ ។*

*៩-សហប្រតិបត្តិការជាមួយភ្នាក់ងារប្រតិបត្តិការ យោងលើសន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀង ឬច្បាប់អន្តរជាតិ និងភ្នាក់ងារប្រឆាំងអំពើពុករលួយ នៃប្រទេសដទៃទៀតបាន ។*

***មាត្រា ១១ :** សុំកែប្រែទៅជា ***ការបង្កើតអគ្គលេខាធិការដ្ឋានប្រឆាំងអំពើពុករលួយ***

*ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានប្រឆាំងអំពើពុករលួយមួយ ដែលមានឯករាជ្យភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួន ជាសេនាធិការ ។*

*អគ្គលេខាធិការដ្ឋានប្រឆាំងអំពើពុករលួយ ដឹកនាំដោយអគ្គលេខាធិការ ១ (មួយ) រូប និងអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។*

*អគ្គលេខាធិការ និងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ។*

***មាត្រា ១៣ ១៤ និងមាត្រា ១៥:** សុំកែប្រែគ្រប់ពាក្យ អង្គភាពប្រឆាំងអំពើពុករលួយ មកជា ***អគ្គលេខាធិការដ្ឋានប្រឆាំងអំពើពុករលួយ*** ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចប្រធានរដ្ឋសភា មេត្តាពិនិត្យដាក់សំណើសុំធ្វើវិសោធនកម្មនេះ ទៅក្នុងសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ ដោយចាត់ទុកជាការប្រញាប់ ដោយក្តីអនុគ្រោះ ។

សូមសម្តេចប្រធានរដ្ឋសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០

**ហត្ថលេខា**